ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១៣២៦ ព.ណ.ស.ជពកព

ថ្ងៃអង្គារ ៥កើតខែពិសាខ ឆ្នាំមមីអដ្ឋស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា ក្រសួងមហាផ្ទៃ និងសុវត្ថិភាពនៃសាធារណរដ្ឋកូរ៉េ នឹងរៀបចំកម្មវិធីពិព័រណ៍ «K-Safety Expo 2026» ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២-៤ ខែកញ្ញា ឆ្នាំ២០២៦ នៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ។

ព្រឹត្តិការណ៍ពិព័រណ៍ឆ្នាំ២០២៦នេះ នឹងផ្តល់ឱកាសដល់ពាណិជ្ជករ ក្នុងការបង្កើតធុរកិច្ចថ្មីៗ ជាពិសេសលើវិស័យសុវត្ថិភាព និងសិក្សាស្វែងយល់អំពីសក្តានុពលសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងប្រទេសកូរ៉េ និងតាមបណ្តាប្រទេសនៅតំបន់អាស៊ី។ គណៈកម្មាធិការរៀបចំ នឹងផ្តល់ជូនការបញ្ចុះតម្លៃស្តង់តាមប្រភេទស្តង់ និងការចុះឈ្មោះដូចខាងក្រោម៖

- ការបញ្ចុះតម្លៃ១០%សម្រាប់អ្នកកក់មុនត្រឹមថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៦
- ការបញ្ចុះតម្លៃ១០%សម្រាប់ក្រុមហ៊ុនដែលធ្លាប់ចូលរួមតាំងពិព័រណ៍ K-Safety ឆ្នាំ២០២៤ និងឆ្នាំ២០២៥
- ការបញ្ចុះតម្លៃ៥% សម្រាប់ការទិញស្តង់ចាប់ពី៤-៩ស្តង់ និង ១០% ចាប់ពី១០ស្តង់ឡើងទៅ។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួលព្រឹត្តិការណ៍ខាងលើ សូមអញ្ជើញ លោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជន ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមពិព័រណ៍ខាងលើ សូមទំនាក់ទំនងមកស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ តាមរយៈអ៊ីម៉ែល៖ camemb.kr@mfaic.gov.kh / ccr_korea@moc.gov.kh ឱ្យបានមុនថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៦៕

**សូមអរគុណ!**

https://go.gov.kh/moc/th5cay
GO.gov.KH

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N°1.326.MOC.D/TPEA

Phnom Penh, 21 April 2026

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all traders and the public that the Ministry of the Interior and Safety of Republic of Korea will organize "K-Safety Expo 2026", to be held from 2-4 September 2026 at BEXCO in Busan, Republic of Korea.

The K-Safety Expo 2026 will provide an excellent opportunity for businesspersons to establish new ventures in the safety sector and explore the potential cooperation in Korea and across Asia. The organizing committee will offer booth discounts based on booth type and registration conditions, as follows:

-10% discount for early bookings made by 5 May 2026.

-10% discount for companies that previously participated in K-Safety Expo 2024 and 2025.

-5% discount for the purchase of 4-9 booths and 10% discount for 10 booths or more.

In this regard, the Ministry of Commerce, as a facilitator, would like to invite Cambodian traders and the public who are interested in aforementioned event to kindly contact the Royal Embassy of the Kingdom of Cambodia to the Republic of Korea via Email: camemb.kr@mfaic.gov.kh / ccr_korea@moc.gov.kh by 5 May 2026.

https://go.gov.kh/moc/th5cay

GO.gov.KH

THANK YOU!

Ministry of Commerce, Lot 19-61, Russian Federation Blvd, Phum Teuk Thla,
Sangkat Teuk Thla, Khan Sen Sok, Phnom Penh,Kingdom of CAMBODIA

Phone/Facsimile: (855) 23 866 469